**Declassified to Public**
**05 May 2021**

លេខ / No: D108

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**
**Royaume du Cambodge**
**Nation Religion Roi**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

**លេខសំណុំរឿង: ០០៤/០៧-០៩-២០០៩/អ.វ.ត.ក./ក.ស.ច.ស.**

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

ចំពោះមុខ ៖ **ចៅក្រម យូ ប៊ុនឡេង**

**ចៅក្រម Laurent KASPER-ANSERMET**

កាលបរិច្ឆេទ ៖ ថ្ងៃទី ខែកុម្ភៈ ឆ្នាំ២០១២

ភាសា ៖ អង់គ្លេស

ចំណាត់ថ្នាក់ឯកសារ ៖ សម្ងាត់

# ការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ

## វិធាន ២១.១ឃ

**<u>សហព្រះរាជអាជ្ញា</u>**

លោកស្រី ជា លាង

លោក Andrew CAYLEY

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 23 / 03 / 2012
ម៉ោង (Time/Heure): 9:30am
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: [signature]

00786781

០០៥/០៧-០៩-២០០៩/អ.វ.ត.ក./ក.ស.ច.ស. លេខ/No: D108

យើង **Laurent Kasper-Ansermet** សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អ.វ.ត.ក.”)

**ជូនដំណឹងដល់**

អ្នកស្រី **អ៊ឹម ចែម** សញ្ជាតិខ្មែរ កើតនៅឆ្នាំ ១៩៤៦ នៅភូមិក្បាលអូរ ឃុំជាងទង ខេត្តតាកែវ (ប្រទេសកម្ពុជា) ជាកូនស្រីរបស់ឈ្មោះ អៀច អ៊ីវ និងប៉ុត ជឹម បច្ចុប្បន្នរស់នៅក្នុងភូមិអូរអង្រែ ឃុំត្រពាំងតាវ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ឲ្យបានជ្រាបថា៖

១. អ្នកស្រី ត្រូវបានជាប់ឈ្មោះថាជាជនសង្ស័យម្នាក់នៅក្នុងកិច្ចស៊ើបសួរកំពុងបន្តដំណើរការ ដោយយោងតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទីបីរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ ២០០៨ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១ ទាក់ទិននឹងការធ្វើផែនការ ការញុះញង់ ការបញ្ជា ការជួយនិងជំរុញ ឬការប្រព្រឹត្តជាបុគ្គល ឬដោយចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម ចំពោះបទឧក្រិដ្ឋខាងក្រោមដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក៖

ក. អំពើមនុស្សឃាត អំពើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញខាងសាសនាអ៊ីស្លាម (មាត្រា ២០៩, ២១០, ៥០០, ៥០១, ៥០៣, ៥០៤, ៥០៥, ៥០៦, ៥០៧, និង ៥០៨ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦) ដែលត្រូវផ្តន្ទាទោសតាមមាត្រា ៣(ថ្មី), ២៩(ថ្មី) និង ៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក

ខ. ការរំលោភបំពានលើអនុសញ្ញាឆ្នាំ ១៩៤៨ ស្តីពីការទប់ស្កាត់ និងផ្តន្ទាសទោសចំពោះអំពើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដែលត្រូវផ្តន្ទាទោសតាមមាត្រា ៤ មាត្រា ២៩(ថ្មី) និងមាត្រា ៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក

គ. អំពើឃាតកម្ម ការសម្លាប់បំផុតពូជ ការដាក់ជាទាសករ ការដាក់ពន្ធនាគារ ការធ្វើទារុណកម្ម ការរំលោភ ការធ្វើទុក្ខបុកម្នេញដោយសារនយោបាយ ពូជសាសន៍ ឬសាសនា និងអំពើអមនុស្សធម៌ផ្សេងទៀត ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងត្រូវផ្តន្ទាសទោសតាមមាត្រា ៥, ២៩(ថ្មី) និង ៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក

ឃ. ការសម្លាប់ដោយចេតនា ការបង្កដោយចេតនាឲ្យមានការរងទុក្ខវេទនាឈឺចាប់ដ៏ធំធេង ឬឲ្យមានរបួសស្នាមធ្ងន់ធ្ងរដល់រូបរាងកាយ ឬសុខភាព ការផ្ទេរ ការធ្វើនិរទេស ឬការឃុំឃាំងជនស៊ីវិលដោយខុសច្បាប់ ដែលជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញានៃ

០០៤/០៧-០៩-២០០៩/អ.វ.ត.ក./ក.ស.ច.ស. លេខ/No: D108

ទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ ដែលត្រូវផ្តន្ទាទោសតាមមាត្រា ៦, ២៩(ថ្មី) និង ៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក

ដោយផ្អែកលើមូលដ្ឋាននៃបទល្មើសដែលបានប្រព្រឹត្តឡើងរវាងឆ្នាំ ១៩៧៦ ដល់ខែ មករា ឆ្នាំ ១៩៧៩ នៅក្នុងប្រទេសកម្ពុជា ក្នុងនាមជាមេដឹកនាំជាន់ខ្ពស់ម្នាក់នៃរបបកម្ពុជាប្រជាធិបតេយ្យ និង/ឬជាបុគ្គលម្នាក់ដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានលើកឡើងខាងលើ ក្នុងតួនាទីរបស់អ្នកស្រីជាលេខាស្រុកកោះអណ្តែត តំបន់១៣ ភូមិភាគនិរតី ពីឆ្នាំ ១៩៧៦ ដល់ខែ មិថុនា ឆ្នាំ ១៩៧៧ ជាលេខាស្រុកព្រះនេត្រព្រះ តំបន់៥ ភូមិភាគពាយ័ព្យ ហើយបានអនុវត្តសិទ្ធិអំណាចក្នុងតំបន់៥ទាំងមូលនៃភូមិភាគពាយ័ព្យ ពីខែ មិថុនា ឆ្នាំ ១៩៧៧ ដល់ខែ មករា ឆ្នាំ ១៩៧៩ ។ ជនរងគ្រោះដែលមានចំនួនដ៏ច្រើនបញ្ជាក់ពីលក្ខណៈធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលអ្នកស្រីត្រូវបានចោទប្រកាន់។

២. ការចោទប្រកាន់ទាំងនេះគឺផ្អែកលើមូលដ្ឋានទាំងអង្គហេតុដែលត្រូវបានចោទប្រកាន់ដោយសហព្រះរាជអាជ្ញា និងអង្គហេតុដែលត្រូវបានរកឃើញនៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ។

៣. ដោយអនុលោមតាមច្បាប់ អ្នកស្រីត្រូវចាត់ទុកថាគ្មានទោស ដរាបណាពិរុទ្ធភាពរបស់អ្នកស្រី មិនទាន់ត្រូវបានរកឃើញ ហើយយើងនៅតែអាចរង់ចាំស្តាប់ចម្លើយភស្តុតាងពីអ្នកស្រី ទាក់ទងនឹងការចោទប្រកាន់ទាំងនេះប្រសិនបើអ្នកស្រីមានបំណងផ្តល់ភស្តុតាងបែបនេះ។

៤. ដោយអនុលោមតាមវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក [វិធាន ២១(១)(ឃ)] សិទ្ធិ និងការធានានៅក្នុងកិច្ចដំណើរការនីតិវិធីក្នុងឋានៈជាជនសង្ស័យ រួមមាន សិទ្ធិមានមេធាវីការពារខ្លួនតាមការជ្រើសរើសរបស់ខ្លួន សិទ្ធិមានលទ្ធភាពទទួលបានឯកសារសំណុំរឿង (អនុវត្តស្របៀងគ្នាតាមវិធាន ៥៥(៦) វិធាន ៥៥(១) និងវិធាន ៥៨ លើកលែងតែបញ្ញត្តិនៃវិធាន ៥៨(៦) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក) និងសិទ្ធិនៅស្ងៀមមិនឆ្លើយតបនៅគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធី។

៥. ជាការចាំបាច់ យើងសូមណែនាំដល់អ្នកស្រី ទៅធ្វើការទាក់ទងជាមួយផ្នែកគាំពារការការពារក្តីនៃ អ.វ.ត.ក ដែលមានមុខងារផ្តល់ជូនលោកនូវជំនួយក្នុងការរៀបចំចាត់ចែងមេធាវីការពារសម្រាប់អ្នកស្រី។ ផ្នែកគាំពារការការពារក្តី ក៏អាចផ្តល់ជូនអ្នកស្រី ផងដែរនូវបញ្ជីឈ្មោះមេធាវី ដែលអាចរកបានសម្រាប់ជនគ្រប់រូបដែលមានសិទ្ធិទទួលបានជំនួយផ្នែកច្បាប់នៅចំពោះមុខ អ.វ.ត.ក។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ ២០១២

**សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ**

**Co-juge d'instruction international réserve**

**International Reserve Co- Investigating Judge**

**Laurent Kasper-Ansermet**